បទបង្ហាញ
ស្ដីពី

# ការស៊ើបអង្កេតក្នុងរឿងព្រហ្មទណ្ឌ

# Criminal Investigation


រៀបរៀងដោយ
លោកសាស្ត្រាចារ្យ ស្វាយ សំណាង



*រៀបចំឡើងវិញ និងផ្សព្វផ្សាយបន្ត*
*ដោយ*
*នីតិកោសល*
*ខែភទ្របទ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤*
*ត្រូវនឹងខែកញ្ញា ឆ្នាំ២០២០*

# ការស៊ើបអង្កេតក្នុងរឿងព្រហ្មទណ្ឌ

# Criminal Investigation

## I.សេចក្តីផ្តើម

១.មូលដ្ឋាននីតិវិធី

មូលហេតុអ្វីចាំបាច់ត្រូវមានការស៊ើបអង្កេត?

ការស៊ើបអង្កេតជាផ្នែកមួយនៃដំណាក់កាលនីតិវិធីព្រហ្មទណ្ឌ នៅក្នុងដំណើរការព្រហ្មទណ្ឌចាំបាច់ត្រូវធ្វើ ក្នុងប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌ ។

ការស៊ើបអង្កេត ជាមធ្យោបាយត្រឹមត្រូវ មិនថាឡើយតែមានអនុវត្តនៅក្នុងប្រព័ន្ធច្បាប់ Civil Law នៅក្នុងប្រព័ន្ធ Comon Law ក៏ដូចគ្នា តុលាការព្រហ្មទណ្ឌមានយុត្តាធិការជំនុំជម្រះ បុគ្គលមួយក្នុងរឿងព្រហ្មទណ្ឌ លុះត្រាតែមានការស៊ើបអង្កេតរកឃើញថាមានកំហុសក្នុងបទល្មើសព្រហ្មទណ្ឌ និងមានសេចក្តីសម្រេចចោទប្រកាន់ ។

ការបង្កើតវិធានស៊ើបអង្កេត និង អនុវត្តនៅក្នុងដំណើការព្រហ្មទណ្ឌ គឺដើម្បីធានា:

- ការពារ កិត្តិយស សេចក្តីថ្លៃថ្នូរ និង អាយុជីវិតរបស់ពលរដ្ឋ
- មិនឱ្យបុគ្គល ដែលគ្មានកំហុស ត្រូវរងទណ្ឌកម្ម និងត្រូវដោះលែងឱ្យមានសេរីភាព ។
- មិនឱ្យបុគ្គលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌរួចផុតពីការទទួលខុសត្រូវ ។
- ដំណើការការដោយគោរពបានតាមគោលការណ៍សន្មត់ជាមុនថាគ្មានទោស ។
- ការចោទប្រកាន់ ការឃាត់ ការចាប់ ការឃុំខ្លួន នឹងអាចធ្វើទៅបាន ដោយអនុលោមទៅតាមច្បាប់ ។

## ២.សេចក្តីសង្ខេបទិដ្ឋភាពនៃការស៊ើបអង្កេត

កាលណាមានបទល្មើសកើតឡើង ត្រូវបង្ក្រាប តាមរយៈការស៊ើបអង្កេត តាមប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌ ។

ការស៊ើបអង្កេត ការស៊ើបអង្កេតត្រូវបានបែងចែកជាដំណាក់កាល:

- ដំណាក់កាលស្វែងរក
- ដំណាក់កាលរកឃើញ
- ដំណាក់កាលស្រាវជ្រាវ
- ដំណាក់កាលកសាងសំណុំរឿង

គុណភាពនៃការស៊ើបអង្កេត:

- គ្រប់ជ្រុងជ្រោយ(ក្នុងលក្ខខណ្ឌលម្អិត)
- បច្ចេកទេស (តម្លាភាព ស្របតាមនីតិវិធី)
- ត្រឹមត្រូវ(មិនបំផ្លើស មិនកាត់បន្ថយការពិត ស្តាប់ភស្តុតាងដែលជាអ្នកនិយាយ)
- ភស្តុតាងត្រូវមានហួសពីវិមតិសង្ស័យ
- លេខឯកសារចុះតាមលំនាំបច្ចេកទេស

## II.អត្ថន័យ និងខ្លឹមសារនៃការស៊ើបអង្កេត

ការស៊ើបអង្កេត គឺជាការស្វែងរកពត៌មានត្រឹមត្រូវ ដើម្បីកំណត់ការពិត ។ ភស្តុតាង ត្រូវដើរតួនាទីដ៏សំខាន់នៅក្នុងទិដ្ឋភាពនៃការស៊ើបអង្កេត ។ ការស៊ើបអង្កេតទាមទារឱ្យធ្វើ ដោយហ្មត់ចត់ គោរពឱ្យបានត្រឹមត្រូវតាមវិធានច្បាប់ ដែលតម្រូវឱ្យធ្វើការស្រាវជ្រាវរហូតទាល់តែរកឃើញចម្លើយថា មានរឿងអ្វីកើតឡើង? នណាអ្នកទទួលខុសត្រូវ?

អ្នកស៊ើបអង្កេតត្រូវមានចំណេះដឹងខាងច្បាប់ បច្ចេកទេស និងទេពកោសល្យ ទើបមានសមត្ថភាពនាំយកបុគ្គលដែលប្រព្រឹត្តខុសក្នុងបទល្មើសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ។

### ១.តួនាទីភស្តុតាង

#### ១.១ សារៈសំខាន់ និង អត្ថន័យ

ភស្តុតាង គឺជាអ្វីៗ ដែលអាចផ្តល់ព័ត៌មានពីហេតុការណ៍ ដែលត្រូវស៊ើបអង្កេត អាចមានដូចជា វត្ថុ ស្លាកស្នាម សំណល់  សរីរៈ ការសង្កេតរបស់អ្នកស៊ើបអង្កេត សក្ខីកម្មរបស់សាក្សី ជនរងគ្រោះ ជនសង្ស័យ ឯកសារ និង ការវិភាគរបស់អ្នកជំនាញ ។

ការស៊ើបអង្កេត ជួនកាលត្រូវបានគេប្រៀបប្រដូចទៅនឹងការដំឡើងរូបភាពនៃល្បែងល្បងប្រាជ្ញា ភស្តុតាងនីមួយៗប្រៀបដូចគ្នាទៅនឹងបំណែកមួយៗនៃរូបភាពនោះ ។ ធ្វើការប្រៀបធៀបបែបនេះ គឺមានប្រយោជន៍ណាស់ ក្នុងការមើលឃើញថា តួនាទី  ភស្តុតាងបានដើរតួគ្រប់ទិដ្ឋភាពនៃការស៊ើបអង្កេតទាំងអស់ ។


SMART
11:19 AM
97%
News Feed
Requests
Messages
Notifications
More



# ១.៣ ចំណាត់ថ្នាក់ភស្តុតាង

- ប្រភេទ វត្ថុ សំណល់ សរីរៈ ស្លាកស្នាម
  (Physical Evidence)
  - ក្រោសលវិច្ឆ័យ
  - មិនចេះភូតភរ
    បង្ហាញពីអ្នកនិយាយ
    កុហក
    ការពិត




- ប្រភេទ សក្ខីកម្ម
  (Testimonial Evidence)
  - សាក្សី
  - ជនរងគ្រោះ
  - ជនសង្ស័យ
- ប្រភេទ ឯកសារ
  (Documentary Eviden)
  - លិខិតស្នាម ឯកសារ សេចក្តីសម្រេច
  - សារព័ត៌មាន
  - ភាពយន្ត




collar. The wound on the right is an exit wound. It is larger, not as round, and shows skin that was torn as the bullet left the body.

## ២.គោលការណ៍ និង គុណភាពនៃការស៊ើបអង្កេត

### ២.១ គោលការណ៍ស៊ើបអង្កេត

ការស៊ើបអង្កេតធ្វើបានតែលើអំពើទាំងឡាយណាជាបទល្មើស

- «នគរបាលយុត្តិធម៌មានភារកិច្ចត្រួតពិនិត្យ បទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ។»ម.៥៦នៃក្រ.នី ។

មូលដ្ឋាននៃការស៊ើបអង្កេត

ការណាបានដឹងពីបទល្មើស

- «កាលណាបានដឹងអំពើអាចជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតដោយឯកឯង ឬ តាមការសុំរបស់ព្រះរាជអាជ្ញា»ម.១១១,ក្រ.នី
- «ក្នុងករណី បទឧក្រិដ្ឋ បទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ។ មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស ។»ម.៨៩,ក្រ.នី

### មូលដ្ឋានស្របច្បាប់នៃការចាប់ផ្តើមស៊ើបអង្កេត

- ប្រភពព័ត៌មាន
  - មនុស្ស
  - សារព័ត៌មាន
  - បណ្តាញសង្គម
  - ឯកសារ
  - ការសង្កេត
- ហេតុផលសង្ស័យ
  - ផ្អែកលើអង្គហេតុជាក់លាក់ មួយ ឬ ច្រើន មានអំពើ គួរឱ្យជឿជាក់ជាបទល្មើស ។

- **ប្រភពពីមនុស្ស**
  - ដាក់ពាក្យបណ្តឹង




សាស្ត្រាចារ្យ ស្វាយ សំណាង

- **បណ្តាញសារព័ត៌មាន**
  - កាសែត
  - ទូរទស្សន៍
  - វិទ្យុ

**បណ្តាញសង្គម**
  - Facebook



ឯកសារ



ឯកសារ



...ENTERPRISE (CAMBODIA) PTE LTD

Profit & Loss Statement

01-JAN-2010 to 20-MAY-2011

04/02

| | | | |
|---|---|---|---|
| Sales Revenues | | | $ 498,292.40 |
| TOTAL NET REVENUE | | | $ 498,292.40 |
| | Beginning stock | $ 69,509.84 | |
| Add: | Good Imported - CTNR# 140 | $ 13,971.12 | |
| | Good Imported - CTNR# 141 | $ 45,617.83 | |
| | Good Imported - CTNR# 142 | $ 40,483.34 | |
| | Good Imported - CTNR# 143 | $ 45,973.12 | |
| | Good Imported - CTNR# 144 | $ 39,219.05 | |
| | Good Imported - CTNR# 145 | $ 32,159.74 | |
| | Good Imported - CTNR# 146 | $ 35,365.46 | |
| | Total Stock available for sales | $ 322,299.49 | |
| Less: | Ending Stock | $ 53,020.52 | |
| | Costs of Goods Sold | | $ 269,278.97 |
| Gross Profit | | | $ 229,013.43 |
| Less: | Operating Expenses | | |
| | Jan-10 | | |
| | Feb-10 | $ 6,202.71 | |
| | Mar-10 | $ 5,973.95 | |
| | Apr-10 | $ 4,818.02 | |
| | May-10 | $ 5,196.53 | |
| | Jun-10 | $ 6,510.01 | |
| | Jul-10 | $ 4,795.45 | |
| | Aug-10 | $ 4,771.81 | |
| | Sep-10 | $ 4,805.92 | |
| | Oct-10 | $ 6,129.72 | |
| | Nov-10 | $ 6,562.41 | |
| | Dec-10 | $ 6,489.44 | |
| | Jan-1[illegible] | $ 8,464.21 | |
| | | $ 7,003.21 | |
| | Total Operating Expenses | | $ 77,723.38 |
| Net Profit | | | $ 151,290.06 |

Approved by:

CHUA HENGYONG

Managing Director

17.01.12

- ## ការសង្កេត
  - ការធ្វើលទ្ធកម្ម ទីតាំង និង អាគារ នៃស្ថាប័នរបស់រដ្ឋ
    - អាគារ និង ទីតាំង នៅទីប្រជុំជន ដីមានតម្លៃខ្ពស់ ជាថ្នូរមកវិញ ទីតាំង នៅឆ្ងាយ សំណង់អាគារកត់សំគាល់ឃើញមិនមានគុណភាព មិនសមស្របទៅនឹងតម្លៃ ដែលកំពង់មាននៅទីផ្សារ
  - ការកើនឡើងពីទ្រព្យសម្បត្តិ
    - មន្ត្រីជាន់ខ្ពស់ ជាអ្នកគ្រប់គ្រងគម្រោងធ្វើផ្លូវជាតិ លើទឹកប្រាក់រាប់លាន ។ នារីកំណាន់របស់គាត់ មានផ្ទះវិឡាថ្មី រថយន្តទំនើប ពាក់គ្រឿងអលង្ការមានតម្លៃខ្ពស់ សម្លៀកបំពាក់ស៊ីវិល័យ ។ បន្ថែមលើនេះ មានប្រពន្ធ និង កូនបួននាក់ក្នុងបន្ទុក ប្រាក់ខែមន្ត្រីរាជការ ត្រឹមតែពីរលានរៀលប៉ុណ្ណោះ ។

## ២.២ គុណភាពនៃការស៊ើបអង្កេត

- គ្រប់ជ្រុងជ្រោយ: ធ្វើក្នុងលក្ខខណ្ឌលម្អិត
- ច្បាស់លាស់: តម្លាភាព តាមបច្ចេកទេស ស្របតាមគោលការណ៍ & មូលដ្ឋានច្បាប់
- ត្រឹមត្រូវ: មិនបំផ្លើស មិនកាត់បន្ថយការពិត ស្តាប់ភស្តុតាង ដែលជាអ្នកនិយាយ ។
- ឆាប់រហ័ស
- ភស្តុតាងត្រូវមានហួសពីវិមតិសង្ស័យ
- បង់លេខឯកសារ និង ចុះតាមលំនាំបច្ចេកទេស

## ៣.ភារកិច្ច និង តួនាទី នៅក្នុងការស៊ើបអង្កេត

### ភារកិច្ច

- ស្វែងរកឱ្យបានឆាប់ និង បង្ហាញឱ្យឃើញពីបទល្មើស នាំយកអ្នកមានកំហុសក្នុងបទល្មើសព្រហ្មទណ្ឌឱ្យទទួលខុសត្រូវ ។
- មិនឱ្យបុគ្គលដែលប្រព្រឹត្តខុស រួចផុតពីការទទួលខុសត្រូវ និង ត្រូវដោះលែងជនដែលគ្មានកំហុសឱ្យមានសេរីភាព ។
- ញែកឱ្យដាច់ពីបុគ្គល ដែលគ្មានកំហុស មិនឱ្យរងនូវទណ្ឌកម្ម និង ទទួលខុសត្រូវ ។

### តួនាទី

- អ្នកស៊ើបអង្កេតមានតួនាទី ស្វែងរកភស្តុតាង និង ធ្វើជាឯកសារ

## III.ដំណាក់កាលនៃការស៊ើបអង្កេត

### ១.ដំណាក់កាលស្វែងរក

- ដំណាក់កាលដំបូងនៃការស៊ើបអង្កេត ជាដំណាក់កាលស្វែងរកឱ្យបានច្រើន និង ឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន គឺ ប្រមូល និង ធ្វើទៅជាឯកសារ ។
- ដំណាក់កាលនេះ ត្រូវគិតថា តើភស្តុតាងហ្នឹងនាំទៅរកភស្តុតាងដទៃទៀតទេ?
- រាល់ពេលដែលភស្តុតាងថ្មីត្រូវបានរកឃើញ អ្នកស៊ើបអង្កេតត្រូវពង្រីកបន្ថែម ដែលអាចរំពឹងថា មានភស្តុតាងជាច្រើនទៀតនឹងត្រូវរកឃើញ។

### ២.ដំណាក់កាលរកឃើញ

- ភស្តុតាងជាច្រើនបានរកឃើញ និង ធ្វើជាឯកសារ ខណៈដែល ភស្តុតាងខ្លះទៀតមិនទាន់ទទួលបាននៅឡើយ ។
- មិនត្រូវប្រឌិតករណីមួយ ដោយចាប់ផ្ដើមជាមួយនឹងអ្វី ដែលខ្លួនយល់ថា ជាការពិត ដោយបង្កើតការពិតជាមួយនឹងការវាយតម្លៃលំអៀង ឬ ប្រើប្រាស់ភស្តុតាងក្លែងបន្លំ ក្រៅពីត្រូវស្តាប់ភស្តុតាងដែលជា អ្នកនិយាយឡើយ ។
- ត្រូវតែត្រួតពិនិត្យដោយហ្មត់ចត់ និង ផ្អែកលើភស្តុតាងទាំងអស់នោះ ពិចារណាតាមទ្រឹស្តី អាចកំណត់បានពីអង្គហេតុ និង/ឬ ក៏អាចកំណត់បានពីអត្តសញ្ញាណជនសង្ស័យ ។

## ៣.ដំណាក់កាលស្រាវជ្រាវ

- ស្រាវជ្រាវរកភស្តុតាងបន្ថែម ។
- ភស្តុភស្តុតាង ដែលស្រាវជ្រាវរកឃើញបាន មួយចំនួនអាចគាំទ្រ និង មួយចំនួនអាចច្រានចោលនូវអ្វី ដែលយល់ពីមុនមក ។
- មានធ្វើកោសលវិច្ឆ័យលើឯកសារ រកឯកសារ ស្តាប់ចម្លើយសាក្សីពិស្តារ ឬ សាក្សី ដែលមិនទាន់បានស្តាប់ចម្លើយ ។

## ៤.ដំណាក់កាលកសាងសំណុំរឿង

- អ្នកស៊ើបអង្កេត ត្រូវតែច្បាស់ក្នុងគំនិត មានរឿងអ្វីកើតឡើង នណាទទួលខុសត្រូវ ដោយផ្អែកលើភស្តុតាងដែលមាន គួរឱ្យទុកចិត្ត និង គួរឱ្យជឿជាក់ និង ច្បាប់ ដែលត្រូវអនុវត្ត។
- អ្នកស៊ើបអង្កេតត្រូវតែរកឱ្យឃើញចន្លោះប្រហោងនៅក្នុងភស្តុតាង និង ដាក់យុត្តិសាស្រ្តរកស្វែងរក ដើម្បីយកមកភ្ជិតនៅកន្លែងខ្វះចន្លោះនោះ។
- ដំណាក់កាលកសាងសំណុំរឿង ភស្តុតាងត្រូវតែមានហួសពីវិមតិសង្ស័យ ។

## IV. ព្រំដែននៃការស៊ើបអង្កេត

- ត្រូវរិះគិតជាដំបូង កន្លែងណាខ្លះ ដែលត្រូវទៅ ។ ការខកខានក្នុងការធ្វើដូច្នេះ ជាលទ្ធផល អាចបាត់បង់ភស្តុតាងដ៏សំខាន់ ហើយក៏អាចបង្ករឱ្យមានផលប៉ះពាល់ដល់ការស៊ើបអង្កេតទាំងមូល ។
- កន្លែងស៊ើបអង្កេត *គឺជាកន្លែង ដែលអាចមានភស្តុតាងទាក់ទងនឹងហេតុការណ៍ ដែលត្រូវស៊ើបអង្កេត ។*
- អ្នកស៊ើបអង្កេតត្រូវតែគិតឱ្យបានឆាប់ និង សិក្សាឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីធ្វើផែនការស៊ើបអង្កេត។ មធ្យោបាយ ប្រសិទ្ធិភាពនោះ គឺ:

កិច្ចការបឋមត្រូវធ្វើ

១) ជនរងគ្រោះ មិត្តភក្តិ សាច់ញាតិ ឬ ក្រុមគ្រួសារជនរងគ្រោះ។

២) សាក្សីដែលបានឃើញ ហេតុការណ៍។

៣) សាក្សីដែលអះអាងថា បានដឹងនណាប្រព្រឹត្តរឿងនោះ។

ស្តាប់ ឬ ធ្វើទំនាក់ទំនងទៅ

បណ្តាញសាព័ត៌មាន។

## កន្លែងដែលអាចត្រូវស៊ើបអង្កេត

- កន្លែងដែលជនរងគ្រោះស្ថិតនៅ មុន ឬ ក្នុងអំឡុង ឬ ក្រោយពេលកើតហេតុ
  - មន្ទីពេទ្យដែលជនរងគ្រោះព្យាបាល
  - ផ្ទះជនរងគ្រោះ
  - កន្លែងធ្វើការរបស់ជនរងគ្រោះ
  - យានយន្តដែលជនរងគ្រោះធ្វើដំណើរ
  - ផ្លូវ ចូល និង ចេញ ពីកន្លែងកើតហេតុ
- កន្លែងដែលជនសង្ស័យស្ថិតនៅ មុន ឬ ក្នុងអំឡុង ឬ ក្រោយពេលកើតហេតុ
  - រថយន្តរបស់ជនសង្ស័យ
  - កន្លែងធ្វើការ
  - ផ្ទះ
  - ផ្លូវ ចូល និង ចេញពីកន្លែងកើតហេតុ
  - កន្លែងដែលបានប្រមូលផ្តុំមុនធ្វើផែនការវាយប្រហា
  - កន្លែងដែលបានប្រមូលផ្តុំមុនធ្វើផែនការវាយប្រហា

❑ ពាក់ព័ន្ធនឹងបទល្មើសពុករលួយ ព្រំដែននៃការស៊ើបអង្កេតត្រូវគិតពិចារណាដល់:

- ការតាមដានប្រាក់
  - ត្រួតពិនិត្យចំនួនប្រាក់
  - ប្រាក់ចំណាយ
- ត្រូវរកអ្នកព័ន្ធជាមួយជនសង្ស័យ
  - ភរិយា, កូន, ឪពុកម្ដាយ, អ្នកស្និតស្នាល, មនុស្សផ្សេងទៀត (កូនបំណុល, អ្នកស៊ីស្នួលគ្រប់គ្រងទ្រព្យសម្បត្តិ)
- ស្រាវជាវ
  - ទីកន្លែងចុះបញ្ជីអចលនវត្ថុ
  - អាជីវកម្ម
  - ធនាគា

## V.ការអនុវត្តនៅកន្លែងស៊ើបអង្កេត

### ១.ការការពារ

- *នៅពេលមកដល់កន្លែងកើតហេតុ ការទទួលខុសត្រូវរបស់អ្នកស៊ើបអង្កេត គឺមានអ្វីកើតឡើងនៅទីនោះ ខណ:ដែលមិនទាន់កុតាប់បានពីភស្តុតាងដែលជាប់ពាក់ព័ន្ធ អ្នកស៊ើបអង្កេតមានភារកិច្ចទទួលខុសត្រូវចំពោះ ភស្តុតាងដែលនាំទៅរក ឬ ភស្តុតាងដែលជាប់ពាក់ព័ន្ធ នៅពេលទៅដល់កន្លែងកើតហេតុ។*
- *កិច្ចសំខាន់ដែលត្រូវធ្វើបន្ទាន់ គឺវិធានការ ដែលធានាដល់សន្តិសុខភស្តុតាង ពោលគឺ កន្លែងស៊ើបអង្កេតត្រូវតែការពារ ដើម្បីបញ្ចៀសបាន ពីការនាំមក ឬ ធ្វើឱ្យបាត់បង់ ភស្តុតាង ។*

## ២.ការសង្កេត

- មុននឹងដំណើរការយកភស្តុតាងនៅកន្លែងស៊ើបអង្កេត សំខាន់ណាស់ថា ត្រូវត្រួតពិនិត្យដោយប្រុងប្រយ័ត្ន និង ធ្វើជាឯកសារ នូវការសង្កេតរបស់ខ្លួន។
- ត្រូវយកពេល ១០ ទៅ ១៥នាទី ពិនិត្យមើល នៅកន្លែងស៊ើបអង្កេត និងសិក្សាពីអ្វីៗដែលគួរឱ្យកត់សម្គាល់មាននៅទីនោះ។

*ព្យាយាមសញ្ជឹងគិត:*

*តើមានរឿងអ្វីដែលអាចកើតឡើង? តើកន្លែងកើតហេតុអាចមានរូបរាងយ៉ាងម៉េចមុនពេលកើតហេតុ? និងថា តើមានអ្វីដែលត្រូវប្រែប្រួលក្នុងអំឡុងពេលកើតហេតុ?*

Careful examination of a stab wound can also indicate the type of knife used. Knives can be divided into three categories. The most common knife has only one sharpened edge. The other side of the blade is thicker and smoother than the sharpened side. A dagger is a knife on which both sides of the blade have been sharpened. Both sides are symmetrical, equally sharp, and cut equally well. A saw-tooth knife is a special knife used by some military units for outdoor survival. This knife, like the common knife, also has one sharpened side and a thicker spine. The distinguishing feature of this knife is the back edge, which has sharpened saw-teeth. These teeth allow the knife to be used to cut wood. In some countries this knife is referred to as a "Rambo" knife after a movie in which the hero carried one.



**Each of the above photographs shows a weapon and the different stab wound that it caused. Careful examination of a victim's injuries can help the investigator identify which objects at the investigative scene could have been used as the weapon. Consultation with a forensic pathologist is necessary for any definitive determination.**





ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
គំនូសបំព្រួញ នៃទីកន្លែងកើតហេតុ
-ករណីប្រទះឃើញសាកសព នៅចំណុចចន្លោះបង្គោលគីឡូម៉ែត្រលេខ ១០២-១០៣ ផ្នែកខាងជើង ផ្លូវជាតិលេខ៤ ចំងាយ ៥០ម ស្ថិតក្នុងភូមិសាស្ត្រភូមិទី៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។
-ប្រទះឃើញសាកសព ថ្ងៃទី ២១-០៣-២០១៤ វេលាម៉ោង ០៨:៣០ នាទី ។
5m
3m
50m
ផ្លូវជាតិលេខ៤
Km103
Km102
គំនូសតាងសំគាល់
=ចំណុចសាកសព ( ម្តាយ )
=ចំណុចសាកសព ( កូន )
=បង្គោលគីឡូម៉ែត្រ
បានឃើញ និងឯកភាព
កំពង់ស្ពឺ.ថ្ងៃទី....ខែ....ឆ្នាំ ២០១៤
កំពង់ស្ពឺ.ថ្ងៃទី....ខែ....ឆ្នាំ ២០១៤

## ៥.ការប្រមូល

- បន្ទាប់ពីបញ្ចប់ការថត និង គូ កន្លែងកើតហេតុ ដល់ពេលដែលត្រូវប្រមូល និង ដាក់ការសម្គាល់។ ចម្មតាការប្រមូលភស្តុតា អ្នកត្រូវគិតថា  តើអ្វីខ្លះត្រូវយក និង របៀបយកត្រូវធ្វើដូចម្ដេច ដើម្បីកុំឱ្យប៉ះពាល់អាផ្សេងទៀតដែលនៅសល់ ?
- វាជាការលំបាកមួយពីព្រោះ អ្នកអាចយល់ពីសារសំខាន់ វត្ថុនីមួយៗ បន្ទាប់ពីស្ដាប់ ឬ ជជែកជាមួយសាក្សី និង នីតិវិធីទាំងអស់ដែលបានធ្វើនៅកន្លែងស៊ើបអង្កេត ។
- ភាពត្រឹមត្រូវ ត្រូវយកតែអ្វី និង រក្សាតែវត្ថុណា ដែលជាប់ពាក់ព័ន្ធ និង ផ្តល់ព័តមានពីហេតុការណ៍ ។ ប្រសិនបើ មានការសង្ស័យត្រូវប្រមូលយក និង បើមិនពាក់ព័ន្ធមិនមែនជាការលំបាកទេក្នុងការប្រគល់ឱ្យវិញ ចៀសវាងការខកខាន ដែលនាំឱ្យបាត់បង់ ។



# VI. ការធ្វើឯកសារភស្តុតាង

១.គោលការណ៍

- *ប្រភពឯកសារជាព័ត៌មាន ដែលនាំឱ្យមានមូលដ្ឋាននៃការចាប់ផ្តើមស៊ើបអង្កេត*
- *គ្រប់បេសកកម្មស៊ើបអង្កេត ត្រូវធ្វើជារបាការណ៍អនុវត្ត អ្វីដែលបានយកត្រូវមាន ឈ្មោះ និងធ្វើកំណត់ហេតុ និងហត្ថលេខារបស់អ្នកធ្វើ ក្នុងកំណត់ហេតុ និងរបាយការណ៍ ។*
- *កាលបើការស្តាប់ ឬ សួរចម្លើយ បានប្រើប្រាស់ឱ្យអ្នកឆ្លើយពន្យល់ ត្រូវចុះឈ្មោះឯកសារនោះ ហើយដាក់ភ្ជាប់ជាមួយកំណត់ហេតុចម្លើយ ។ កាលណាមានថតរូប ថតសម្លេង ត្រូវប្រាប់អ្នកឆ្លើយជាព័ត៌មាន និង ត្រូវផ្តល់ឱ្យអ្នកឆ្លើយ ដាក់ក្នុងស្រោមសំបុត្របិតជិត ដោយចុះហត្ថលេខា/ផ្តិតមេដៃនៅកន្លែងបិទ និង បិទស្កុតមួយជាន់ពីលើ ។*
- *ក្នុងករណី ដែលឯកសារនោះ ត្រូវព្រីន ឬថត ត្រូវឱ្យជាប់ឈ្មោះប្រភព ដែលទទួលបាន*
- *បង់លេខឯកសារភស្តុតាង និង ចុះតាមលំដាប់លំដោយនៃលេខរាងឯកសារ នៃបញ្ជីរាយលិខិត (និង ពីព័ត៌មានដែលបានទទួល)*

២.ការធ្វើឯកសាររបួស

ទំនាក់ទំនងជាមួយអ្នកជំនាញ

ណែនាំខ្លួនជាអ្នកស៊ើបអង្កេត និងពន្យល់អំពីគោលបំណង

សួរជនរងគ្រោះ ពីកន្លែងដែលរងគ្រោះ និង ឱ្យរៀបរាប់រឿងហេតុ ដែលបានកើតឡើង។

ថត (ទំហំ ទ្រង់ទ្រាយ ជម្រៅ ស្លាកស្នាម បង្ហាញឱ្យឃើញច្បាប់)

ត្រួតពិនិត្យ (តើបានធ្វើគ្រប់ជ្រុងជ្រោយហើយ ឬនៅ? អាចកត់សម្គាល់ឃើញពីតម្រុយភស្តុតាង)

សួរជនរងគ្រោះពាក់ព័ន្ធនឹងប្រវត្តសុខភាពរបស់គាត់

VII. ការស្តាប់ចម្លើយសាក្សី

## ១.គោលការណ៍

### ទីកន្លែង ដែលត្រូវស្តាប់ចម្លើយសាក្សី

- ការស្តាប់ចម្លើយសាក្សី មិនត្រូវធ្វើនៅកន្លែងដែលងាយគេស្តាប់ឮ ។
- ការស្តាប់ចម្លើយសាក្សី មិនត្រូវធ្វើចំពោះវត្តមានសាក្សីដ៏ទៃទៀត។
- ការស្តាប់ចម្លើយសាក្សី មិនត្រូវធ្វើនៅចំពោះអ្នកផ្សេងដែលមិនមានភារកិច្ច។
- ការស្តាប់ចម្លើយសាក្សី ត្រូវធ្វើនៅកន្លែង ដែលមានសន្តិសុខ និង មិនមានអ្វីរំខាន។

## ២.ការស្តាប់ចម្លើយបឋម

- គោលដៅពិត សម្រាប់ស្តាប់ចម្លើយបឋម អ្នកស៊ើបអង្កេតអាចទទួលបានព័ត៌មានសំខាន់ៗ ដែលមានតម្រូវការក្នុងកំរិតជាការចាប់ផ្តើមការស៊ើបអង្កេត ហើយសាក្សីទាំងនោះអ្នកស៊ើបអង្កេតត្រូវរៀបចំ ដើម្បីស្តាប់យកចម្លើយពិស្តាបន្ទាប់ ។
- ការធ្វើបែបនេះ គឺជួយឱ្យអ្នកស៊ើបអង្កេត ដែលជាប់កាតព្វកិច្ចក្នុងការស្វែងរកអត្តសញ្ញាណសាក្សី និង ការប្រមូលភស្តុតាងមាន **តុល្យភាព**។

ការស្តាប់ចម្លើយបឋម មានគោលដៅបីយ៉ាង:

1) ទទួលបានព័ត៌មានសំខាន់ៗពីរឿងហេតុដែលបានកើតឡើង និង យល់ជាមូលដ្ឋាន ពីអ្វី ជាពិសេស ដែលសាក្សីដឹង និងថា តើសាក្សីនោះទំនងជា ល្អ ឬ អត់។
2) ទទួលបានព័ត៌មាន ដែលនឹងជួយស្វែងរកអត្តសញ្ញាណ និង ភស្តុតាងដទៃទៀត ។
3) កំណត់កាលបរិច្ឆេទ សម្រាប់ការស្តាប់ចម្លើយពិស្តា ..ពីរ ឬ បីថ្ងៃបន្ទាប់ ។

៣.ការស្តាប់ចម្លើយពិស្តារ

- អ្នកសួរបានល្អ គឺជាអ្នកមានលទ្ធភាពទទួលបានព័ត៌ពិត ត្រឹមត្រូវ និង លម្អិត ពីមនុស្ស ដែលគេសួរ។
- ការស្តាប់ចម្លើយពិស្តា មានគោលដៅបួន:
    1) ស្រង់ព័ត៌មានឱ្យអស់ ពីសាក្សី
    2) ប្រមូលព័ត៌មានគ្រប់ជ្រុងជ្រោយ និង វាយតម្លៃ គួរឱ្យទុកចត្តិ និង គួរឱ្យជឿជាក់
    3) សើុបសួរបន្ថែមពីព័ត៌មាន ឬ ភស្តុតាង ដែលសាក្សីបានដឹង
    4) ត្រូវមានព័ត៌មានគ្រាប់គ្រាន់ ដើម្បីទាក់ទងជាមួយសាក្សីនាពេលខាងមុខ

## ប្រើប្រាស់សំណួរ

**សំណួរបើក** Open-ended question — អ្វីខ្លះ ដែលអ្នកបានឃើញពេលទៅដល់កន្លែងកើតហេតុ?

**សំណួរជាក់លាក់** Specific question — ពេលទៅដល់កន្លែងកើតជនសង្ស័យនៅកន្លែងណាជាប្រាកដ?

**សំណួរនាំមុខ** Leading question — អ្នកឃើញជនសង្ស័យកំពង់ឈរក្បែររថយន្តត្រូវទេ? (កុំប្រើ)

- «ខ្ញុំជឿថា អ្នកបានឮ សៅ ស្រែយំមុននឹងគេបាញ់គាត់ កាលពីថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ២០១៦ ក្បែសាលារៀនទួលគោក»
- ត្រូវនិយាយ «ខ្ញុំជឿជាក់ថា អ្នកមានព័ត៌មានពីអ្វីដែលបានកើតឡើង ហើយរឿងនោះ ខ្ញុំចង់និយាយជាមួយអ្នក»

## VIII ការសួរចម្លើយជនសង្ស័យ

### ១.គោលការណ៍

- អ្នកស៊ើបអង្កេតត្រូវទទួលបានការរៀបរាប់របស់ជនសង្ស័យដោយស្ម័គ្រចិត្តពីអ្វីដែលបានកើតឡើងក្នុងលក្ខណៈលម្អិត ។
- ប្រសិនបើការរៀបរាប់របស់ជនសង្ស័យ ជាការពិត វានឹងស្របគ្នាជាមួយភស្តុតាងដទៃទៀតនៅក្នុងរឿងហេតុស៊ើបអង្កេតនោះ ដូចគ្នាទៅនឹងកាបង្គុំផ្នែកមួយ ៗ នៃល្បែងល្បងប្រាជ្ញា ។
- ប្រសិនបើ ជនសង្ស័យនិយាយប្រាប់ដោយភូតកុហក់ ចម្លើយជនសង្ស័យនឹងផ្ទុយទៅនឹងភស្តុតាងដទៃទៀតនៅក្នុងសំណុំរឿង ដែលស៊ើបអង្កេត មានជាដូចជាក្រយ៉ៅដៃ សក្ខីកម្មរបស់សាក្សី ជនរងគ្រោះ ....។ល។

## ២.គន្លិះសំខាន់នៃការសួរចម្លើយ

- គឺព័ត៌មានលម្អិត អ្នកស៊ើបអង្កេតត្រូវទទួលឱ្យបាន ។
- ការប្រើប្រាស់សំណួរបើក (Open-ended question) និង សំណួរជាក់លាក់ (Specific question) ។ ការប្រើសំណួរជាក់លាក់ គឺ អ្នកស៊ើបអង្កេតប្រឹងប្រែង ដើម្បីទទួលបានព័ត៌មានលម្អិតពីជនសង្ស័យតាម ដែលអាចធ្វើទៅបាន។
- ត្រូវសួរជនសង្ស័យ តាមលំដាប់លំដោយនៃរឿងហេតុទាំងមូល ឱ្យលម្អិត គ្រប់កន្លែង និង វេលាដែលជនសង្ស័យ និង ជនរងគ្រោះស្ថិតនៅ ។
- ប្រសិនបើ ជនសង្ស័យកុហក់ ត្រូវលម្អិតនៅកន្លែងដែលកុហក់នោះ ។

## វិធីមួយទៀត ស្វែងរកចំណុចខុសគ្នា ដើម្បីប្រឆាំងនឹងការដោះសារ

- ធ្វើជាកំណត់ហេតុ ឬ
- ឱ្យជនសង្ស័យសរសេរដោះសារពីអ្វី ដែលគេចង់និយាយ

បីអាទិត្យ ឬ មួយខែក្រោយ សួរ ឬ ឱ្យជនសង្ស័យសរសេរពីរឿងដដែលនោះឡើងវិញ។ ចំណុចខ្លះ ដែលជនសង្ស័យព្យាយាមភូតកុហកពីលើកមុន គេនឹងមិនចាំបាន ហើយចំណុចនោះ ជនសង្ស័យនឹងនិយាយរឿងផ្សេងខុសពី មុន។

## មិនមែនអ្នកប្រកែកទាំងអស់សុទ្ធតែមានកំហុសទាំងអស់ឡើយ

សុខ ស្រី ជាអ្នកបំរើនៅក្នុងផ្ទះ ប៊ុន សុធា ។ ស្រី បានប្តឹង សុធាថា បានជំពាក់ប្រាក់ នាង ចំនួន ១៨០០០ដុល្លារ ។ សុធា ប្រកែកនឹងការចោទប្រកាន់នេះ ស្រីមានកិច្ចសន្យាបង្ហាញ និង បានដាក់ជាភស្តុតាង ។

ធ្វើកោសលវិច្ច័យលើកិច្ចសន្យា លទ្ធផលពីអ្នកជំនាញ (ម.ផ្ទ)

បញ្ជាក់ថា ស្នាមក្រយៅដៃ នៅលើកិច្ចសន្យាដូចគ្នាទៅនឹង សំណាក់ដើមនៃស្នាមក្រយៅដៃរបស់ ប៊ុន សុធា ។

ធ្វើបដិកោសវិច្ច័យទៅ (អ.ហ.ផ្ទៃ/ទេស)។ ជាលទ្ធផល បញ្ជាក់ថា ជាស្នាមក្រយៅដៃស្តែន មិនអាចធ្វើកោសវិច្ច័យបាន ទេ ។ (ព្រៃវែង)

## ការសួរចម្លើយតទល់

ការសួរចម្លើយតទល់ធ្វើក្នុងលក្ខខណ្ឌ ជាច្រើន ដូចជា ដើម្បី សំគាល់អត្តសញ្ញាណដៃលជនសង្ស័យ /សាក្សី ប្រកែក ចំណុចខុសគ្នាលើការផ្តល់ព័ត៌មាន ឬ បញ្ជាក់លើ ឯកសារ ផ្សេងៗ ។ល។

ការសួរតទល់អាចកើតឡើងរវាង:

- សាក្សី និង សាក្សី
- សាក្សី និង ជនរងគ្រោះ
- ជនសង្ស័យ និង សក្សី
- ជនសង្ស័យ និង ជនសង្ស័យ
- ជនត្រូវ និង ជនត្រូវចោទ ...

### សំណួរដែលត្រូវប្រើចាប់ផ្ដើមក្នុងការសួរតទល់

- ស្គាល់អ្នក ដែលមានវត្តមាននៅទីនេះទេ ?
- ចម្លើយស្គាល់ ។
- ស្គាល់ពីពេលណាមក ក្នុងស្ថានភាពដូចម្ដេច ?
- ឱ្យអ្នកត្រូវសួរម្ដងទៀត ឆ្លើយតបទៅនឹងការលើកឡើងរបស់អ្នកឆ្លើយមុន ?

## IX. ការស៊ើបអង្កេតរកជនសង្ស័យ

គ្រប់រឿងព្រហ្មទណ្ឌ ដែលត្រូវស៊ើបអង្កេតមិនត្រឹមតែប្រមូលភស្តុតាង ដើម្បីបង្ហាញតែពីអ្វីកើតមានឡើងទេ ប៉ុន្តែក៏ត្រូវបង្ហាញផងដែរ នណាជាអ្នកទទួលខុសត្រូវ។ តាមនីតិវិធីច្បាប់ ក៏ដូចជាគោលការណ៍តម្រូវ ឱ្យស្វែងរក និង ប្រមូលភស្តុតាងឱ្យធ្វើបានហួសពីវិមិតិសង្ស័យ ។

១.ការកំណត់អត្តសញ្ញាណជនសង្ស័យ

- *សួរសាក្សី/ជនសង្ស័យពីកិនភាគជនសង្ស័យ*
- *តាមរបៀបធ្វើកំណត់សម្គាល់ចង្អុលបង្ហាញ*
  - *មនុស្ស៥នាក់ស្លៀកពាក់ដូចគ្នា ពាក់លេខសម្គាល់*
  - *ឱ្យចង្អុលលើរូបថត ៥ ឬ៦សន្លឹក*
- *តាមរបៀបគូរូប*
- *តាមការពិនិត្យតាមកាមេរ៉ា(អង្គចងចាំ)សុវត្ថិភាព*
- *Physical Evidence*

២.ការស្វែងរកជនសង្ស័យ

- *នាំសាក្សី/ជនសង្ស័យ ឱ្យចង្អុលបង្ហាញ*
- *ឱ្យសាធារណៈជនផ្ដល់ព័ត៌មាន*

## ៣.គំរូសំណួរ

### សំណួរពីភិនភាគ

- អ្នកអាចប៉ាន់ប្រមាណកំពស់ជនសង្ស័យបានទេ ?
- ប្រៀបធៀប ជាមួយអ្នក ទាបជាង ឬ ក៏ខ្ពស់ជាង ?
- ជនសង្ស័យមានមុខមាត់យ៉ាងដូចម្ដេច ? (កាច ស្លូត លក្ខណៈពិសេស...)
- សក់ជនសង្ស័យ ដូចម្ដេច ? (ខ្លី វែង ស្លូត រួញ អង្គាដី ពណ៌...)
- មានច្រមុះយ៉ាងម៉េច ?
- ស្គម ឬ ធាត់? បើប្រៀបជាមួយលោកវិញ ។
- ភ្នែកពណ៌អ្វី ?
- មានកត់សម្គាល់អ្វីនៅកជនសង្ស័យ ? (មានខ្សែក)
- នៅត្រចៀកវិញឃើញមានអ្វីដែរ ? (ក្រវិល..
- ធ្លាប់ស្គាល់ ឬ ដែលឃើញពីមុនដែរ?
- បើបានជួប ឬ ក៏ឃើញ ម្ដងទៀត ស្គាល់ ឬចំណាំបានទេ ?

### ភិនភាគសំម្លៀកបំពាក់

- សម្លៀកបំពាក់យ៉ាងម៉េច? (ពណ៌ អាវ ខោ វែង ខ្លី ម៉ាក ល្មម ចង្អៀត រលង់
- មានកត់សម្គាល់អ្វីជាលក្ខណៈពិសេសដែរ?(ប្រឡាក់ រហែក.)
- មានពាក់ស្បែកអ្វី? (ម៉ូត ម៉ាក ពណ៌...)
- ស្លៀកពាក់ជារបៀប..មន្ត្រីរាជការ បុគ្គលិកក្រុមហ៊ុន? (សម្រាប់អង្គភាពមន្ត្រីរាជការ អត្តលេខ..ឈ្មោះ..សញ្ញា)
- មានស្រោមអាវុធ ឬ ស្រោមកាំបិត ឬ ស្រោមទូរស័ព្ទ ពណ៌.. រូបរាង

### ភិនភាគរថយន្ត

- ពណ៌? ម៉ាក? ឆ្នាំ? កំពិតត្រង់ណា? ពាក់ស្លាកលេខ...? មានបិតស្ទិឃើ ឬ ក៏មានស្នាមអ្វីនៅត្រង់ណា?

# X. ការវិភាគលើការស៊ើបអង្កេត

XI. **របាយការណ៍ស៊ើបអង្កេតនៃសំណុំរឿង លេខ..........ចុះថ្ងៃទី........ខែ..........ឆ្នាំ..........**

## ១.សេចក្តីផ្តើម

១.១ មូលដ្ឋានច្បាប់:

សេចក្តីសម្រេច

ឈ្មោះ និង ឋាន: ក្នុងមុខងារ

១.២ ដំណើការនីតិវិធី

បន្ទាប់ពី ទទួលបានព័ត៌មាន ... យើង សៅ ប៊ុនជា ឋាន:...... និង សឿ សុធា បានធ្វើការស៊ើបអង្កេតសំណុំរឿងនេះ ដោយចាប់ផ្តើមពីថ្ងៃ.....ខែ......ឆ្នាំ... និង បញ្ចប់នៅថ្ងៃទី....ខែ...ឆ្នាំ..... ជាមួយនឹងការប្រមូលបានភស្តុតាងគ្រប់គ្រាន់ ។

## ២.ការកត់សម្គាល់ឃើញពីអង្គហេតុ

អង្គហេតុA អង្គហេតុ ត្រូវសរសេរ រឿងហេតុកើតឡើងតាមរបៀបម៉េច និង ត្រូវបញ្ចប់ទៅតាមរបៀបណា ។ ឧ. កាលពីថ្ងៃទី....

អង្គហេតុB .........

## ៣.ច្បាប់ដែលត្រូវអនុវត្ត

ច្បាប់អ្វី..? មាត្រាណា..?

## ៤.បុគ្គលិកលក្ខណ:របស់បុគ្គល

ជីវប្រវត្តរបស់ជនសង្ស័យមុន និង ក្រោយប្រព្រឹត្តបទល្មើស..។

### ហេតុដូច្នេះសម្រេច

បញ្ជូនសំណុំរឿង និង ជនសង្ស័យឈ្មោះ ... រួមទាំងភស្តុតាង ជូនលោកព្រះរាជអាជ្ញា ដើម្បីចាត់ការតាមច្បាប់ ។

ភ្នំពេញថ្ងៃទី.... ខែ...... ឆ្នាំ........

តួនាទី និង ហត្ថលេខា

## បញ្ជីរាយនាមសំណុំលិខិតនៃសំណុំរឿង

| ល.រ | ឈ្មោះឯកសារ | កាលបរិច្ឆេទ | សន្លឹក | ផ្សេង |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |

ភ្នំពេញថ្ងៃទី......ខែ ...... ឆ្នាំ.....
មន្ត្រីដែលធ្វើ ...
កូនទាទី និង ហត្ថលេខា

Email Address: svay.samnang@yahoo.com
Tel: 011 472222, 0962032039